# សុន្ទរកថា
## ក្នុងឱកាសសមាជលើកទី១
## របស់ប្រធានគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ
**ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១**

ជាបឋមខ្ញុំព្រះករុណាខ្ញុំបាទ **ខឹម វាសនា** សូមក្រាបថ្វាយបង្គំ ព្រះគុណម្ចាស់ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ សូមគោរពសមាជិក សមាជិកានៃអង្គសមាជ និងភ្ញៀវកិត្តិយសទាំងអស់ ជាទីគោរពរាប់អាន។

ពេលនេះខ្ញុំមានសំណួរពីរ សួរទៅកាន់សមាជិកចលនារបស់យើង ៖ ទីមួយ "តើពួកយើងកំពុងតែធ្វើអ្វី?" និងទីពីរ "តើពួកយើងធ្វើនេះដើម្បីអ្វី?"។ សំណួរទីមួយជួយយើងឱ្យមានសតិពេញលេញក្នុងការងាររបស់យើង ចំណែកសំណួរទីពីរជួយយើងឱ្យមានទំនុកចិត្តក្នុងការងាររបស់យើង។ កាលណាអ្នកមានសតិពេញលេញក្នុងការងាររបស់អ្នក ការងាររបស់អ្នកត្រូវបានផ្ចិតផ្ចង់ និងស្ថិតក្នុងភាពអាចគ្រប់គ្រងបាន។ កាលណាអ្នកច្បាស់លាស់ថា អ្នកធ្វើនេះដើម្បីអ្វីពិតប្រាកដ ឥទ្ធិពលអវិជ្ជមានខាងក្រៅមិនអាចបង្វែរទិសសកម្មភាពការងាររបស់អ្នកបានឡើយ។ ទីបំផុត ទោះបីកិច្ចការនេះលំបាកធ្ងន់ធ្ងរប៉ុនណាក៏ដោយ ទោះបីឧបសគ្គដែលអ្នកត្រូវឆ្លងកាត់នោះមានសភាពខ្លាំងក្លាយ៉ាងណាក៏ដោយ អ្នកនៅតែទៅដល់គោលដៅបានយ៉ាងគួរឱ្យស្ញើចសរសើរ។ ពេលនេះ ពួកយើងកំពុងតែរៀបចំសមាជលើកទីមួយរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យរបស់ពួកយើង។ សមាជរបស់យើងកំពុងស្ថិតនៅក្នុងភាពអាចគ្រប់គ្រងបានរបស់ពួកយើង។ ចុះអ្វីទៅជាចម្លើយចំពោះសំណួរទីពីរ? តើពួកយើងកំពុងតែធ្វើសមាជនេះដើម្បីអ្វី? ថ្វីបើការរៀបចំសមាជនៅពេលនេះមានវត្ថុបំណង ជាអាទិ៍ ដើម្បីជ្រើសរើសប្រធានគណបក្ស សម្រេចលក្ខន្តិកៈ ផ្តល់សុពលភាពដល់សមាសភាពគណៈកម្មាធិការកណ្តាល ។ល។ ប៉ុន្តែ នេះគ្រាន់តែជាដំណាក់កាលឆ្លងកាត់ដើម្បីឆ្ពោះទៅរកគោលដៅប៉ុណ្ណោះ។ ចុះតើអ្វីទៅជាគោលដៅ?

យើងត្រូវស្រមៃឱ្យឃើញនូវសុបិនរួមដែលជាគោលដៅរបស់យើង។ វាគឺជាសុបិនរួមដែលពួកយើងទាំងអស់គ្នាបានចូលរួមគ្នាបង្កើតឡើង គឺ ៖ **"មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងនាមជា**

**ម្ចាស់**"។ នេះគឺជាសុបិនរួមដែលជាគោលដៅរបស់ពួកយើង។ ពួកយើងទាំងអស់គ្នាត្រូវធ្វើឱ្យសុបិននេះក្លាយជាការពិតដោយកណ្តាប់ដៃរបស់ពួកយើង។ វិធានការចាំបាច់ជាគន្លឹះ សម្រាប់ឱ្យពួកយើងទាំងអស់មានភាពស្មើគ្នាក្នុងនាមជាម្ចាស់ប្រទេស គឺគោលការណ៍តុល្យភាពអំណាចរវាងពលរដ្ឋជាម្ចាស់ប្រទេស និងរដ្ឋាភិបាលដែលជាតំណាងឆន្ទៈរបស់ពួកយើង។

គោលនយោបាយគន្លឹះរបស់គណបក្សយើង គឺជាទីដែលពួកយើងត្រូវទៅឱ្យដល់ ដើម្បីឱ្យសុបិនរួមរបស់យើង គឺ "**មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងនាមជាម្ចាស់**" បានក្លាយជាការពិត។ ខ្ញុំមានទំនុកចិត្តយ៉ាងច្បាស់ថា បងប្អូនបានធ្លាប់ឮអំពីវា ធ្លាប់ដឹងអំពីវា ធ្លាប់យល់អំពីវា ថែមទាំងធ្លាប់ស្រមៃឃើញរូបរាងដ៏រស់រវើករបស់វាយ៉ាងច្បាស់ ក្នុងខួរក្បាលរបស់បងប្អូនទៀតផង។ តើវាគឺជាអ្វីទៅ? វាគឺជាយន្តការប្រាំបីចំណុច ជាគោលនយោបាយគន្លឹះរបស់គណបក្សយើង ដែលឆ្លុះបញ្ចាំងពីឆន្ទៈដ៏មុតស្រួច និងទស្សនវិស័យដោយផ្អែកលើមូលដ្ឋានពិចារណាប្រកបដោយហេតុផលត្រឹមត្រូវរបស់ចលនាយើង ក្នុងការធ្វើឱ្យសុបិនរួមរបស់យើង ក្លាយជាការពិត។

យន្តការប្រាំបីចំណុចមានដូចតទៅ ៖

១. ត្រូវកំណត់អាណត្តិសម្រាប់នាយករដ្ឋមន្ត្រី (ពីរអាណត្តិ)

២. នាយករដ្ឋមន្ត្រីមិនត្រូវបានអនុញ្ញាតឱ្យបង្កើតក្រុមអង្គរក្សដោយខ្លួនឯងទេ

៣. នាយករដ្ឋមន្ត្រីត្រូវរស់នៅក្នុងនិវេសនដ្ឋាន(ផ្ទះ)ដែលផ្តល់ដោយរដ្ឋ

៤. បង្កើតតុលាការរដ្ឋបាល

៥. ឋានន្តរសក្តិចាប់ពីឧត្តមសេនីយ៍ យោធា និងនគរបាលត្រូវសុំសេចក្តីទុកចិត្តពីសភា

៦. អព្យាក្រឹតមន្ត្រីរាជការ

៧. ប្រជាពលរដ្ឋបោះឆ្នោតដោយផ្ទាល់ ជ្រើសរើស និងទម្លាក់តំណាងគ្រប់ប្រភេទ (ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ និង រាជធានី/ខេត្ត)

៨. ប្រើប្រព័ន្ធឯកត្តនាមសម្រាប់បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ

យន្តការប្រាំបីចំណុចនេះ គឺជាសំណង់រដ្ឋបាលថ្មីមួយ ដែលពួកយើងគ្រប់គ្នាមានកាតព្វកិច្ចជួយជ្រោមជ្រែងសាងសង់ឡើងដើម្បីយកទៅជំនួសប្រព័ន្ធរដ្ឋបាលបច្ចុប្បន្ន ដើម្បីធ្វើឱ្យសុបិនរួមរបស់ពួកយើងគឺ **“មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងនាមជាម្ចាស់”** ក្លាយជាការពិតឡើង។ ពីចំណុចដែលយើងកំពុងតែស្ថិតនៅ ទៅដល់គោលដៅរបស់យើង គឺជាចម្ងាយផ្លូវមួយ។ ជាធម្មតា គ្រប់ការធ្វើដំណើរនៅលើចម្ងាយផ្លូវមួយ តែងតែមានឧបសគ្គ ទោះតូច ឬធំ គឺត្រូវតែមាន។ ចុះអ្វីទៅជាឧបសគ្គក្នុងដំណើរ លើចម្ងាយផ្លូវពីចំណុចដែលយើងកំពុងស្ថិតនៅ ទៅដល់គោលដៅដែលយើងបានកំណត់ទុក?

យើងបានរកឃើញនូវឧបសគ្គធំៗបី គឺ ៖

- រចនាសម្ព័ន្ធនៃអំណាចប្រមូលផ្តុំដែលកំពុងតែមានឥទ្ធិពលយ៉ាងខ្លាំងក្លា គ្របដណ្តប់មាតុភូមិទាំងមូលរបស់យើង ជាឧបសគ្គទីមួយ។
- ចលនានយោបាយនៃគណបក្សក្រៅរដ្ឋាភិបាល ដែលគោលដៅរបស់ពួកគេ គឺធ្វើយ៉ាងម៉េចក៏ដោយឱ្យតែបានសន្លឹកឆ្នោត ហើយដែលកំពុងតែមានប្រជាប្រិយភាពគួរសមដែរ នៅក្នុងចំណោមអ្នកបោះឆ្នោត ដែលជាសម្លេងប្រឆាំងរដ្ឋាភិបាល និងជាអ្នក ដែលមានមូលដ្ឋានពិចារណាទន់ខ្សោយ ជាឧបសគ្គទីពីរ ។
- ភាពអសកម្មរបស់ប្រជាពលរដ្ឋយើងទូទៅ ដែលជាហេតុងាយឱ្យគេបោកប្រាស់បាន មានជាអាទិ៍ ៖ ការគិតតែប្រយោជន៍ផ្ទាល់ខ្លួន ការមិនស្គាល់ពីកាតព្វកិច្ចក្នុងនាមជាម្ចាស់ប្រទេស ការមិនយល់ច្បាស់ពីវត្ថុបំណងត្រឹមត្រូវនៃនយោបាយ ជំនឿស៊ប់ប្រាសចាកហេតុផល ការមិនប្រើសក្តានុពលក្នុងនាមជាមនុស្សឱ្យអស់ និងការមិនអាចវែកញែកចំពោះហេតុការណ៍ទាំងអស់ជុំវិញជីវិតរស់នៅរបស់ខ្លួនបាន គឺជាឧបសគ្គទីបី។

បានឃើញឧបសគ្គ ពួកយើងដឹងយ៉ាងច្បាស់ថា ពីចំណុចស្ថានភាពដែលពួកយើងកំពុងតែស្ថិតនៅ ទៅកាន់គោលដៅដែលយើងបានកំណត់ទុក វាជាកំណាត់ផ្លូវដ៏ស្មុគស្មាញមួយ និងអាចថាជាកំណាត់ផ្លូវដែលប្រកបដោយគ្រោះថ្នាក់ផងក៏ថាបាន។ ដូច្នេះដើម្បីបញ្ចៀសឱ្យបាននូវគ្រោះកាចណាមួយ និងដើម្បីបំបែកឧបសគ្គបានដោយជោគជ័យ ភាពច្បាស់លាស់នូវវិធីសាស្ត្រ ដើម្បីនាំយើងទៅដល់គោលដៅ ដែលយើងហៅថា

***"នយោបាយ"*** និងបាតគ្រឹះដែលជាការកំណត់យក ក្នុងដំណើរនយោបាយរបស់យើង ដែលយើងហៅថា ***"ឥរិយាបថនយោបាយ"*** ត្រូវតែប្រាកដប្រជាក្នុងចិត្តរបស់យើងគ្រប់ៗគ្នា។

- នយោបាយជាសិល្បៈនៃការធ្វើឱ្យបានសម្រេចគោលដៅ ដែលគោលដៅនោះជាផលប្រយោជន៍រួមរបស់យើងទាំងអស់គ្នា។ យើងជាហេតុដើម្បីឱ្យគោលដៅយើងបានសម្រេច ទោះបីយើងមិនបានឈ្នះឆ្នោត ឬឈ្នះឆ្នោតហើយ យើងមិនបានកាន់ការងារស្រុកទេសក៏ដោយ។
- សុចរិតភាព ជាបាតគ្រឹះគ្រប់ឥរិយាបថនយោបាយរបស់ពួកយើង។ គោលការណ៍នេះនឹងជួយឱ្យយើងអាចផ្សះផ្សាជាតិយើង ធ្វើឱ្យខ្មែរយើងអាចសាមគ្គីគ្នា ដែលជាកម្លាំងចាំបាច់ខ្វះមិនបានក្នុងការកសាងជាតិមាតុភូមិរបស់យើង ។ **យើងឈ្លោះគ្នា ព្រោះយើងចង់ឱ្យពួកយើងត្រូវរ៉ូវគ្នា យើងឈ្លោះគ្នាព្រោះយើងចង់ឱ្យពួកយើងសាមគ្គីគ្នា យើងឈ្លោះប្រកែក បែកជាបក្សផ្សេងគ្នា ព្រោះយើងចង់ឱ្យប្រទេសយើងរីកចម្រើនជឿនលឿន។** ***"គ្មានការត្រូវរ៉ូវណាមួយដែលមិនផ្តើមចេញពីជម្លោះទេ"។*** ន័យទាំងអស់នេះអាចសម្រេចបាន គឺសុទ្ធតែផ្អែកទៅលើគោលការណ៍សុចរិតភាពនេះឯង។
- ការចេញទៅឃោសនានយោបាយមិនដើម្បីតម្រង់ទៅរកសន្លឹកឆ្នោតទេ ប៉ុន្តែគឺជាការស្វែងរកការគាំទ្រគំនិត។ ឃ្លានេះ ជួយពញ្ញាក់ស្មារតីឱ្យពួកយើងដឹងថា គ្រប់សកម្មភាពឃោសនានយោបាយរបស់គណបក្សយើងគឺ ទីមួយ **ពន្យល់** ទីពីរ **ពន្យល់** ទីបី ក៏នៅតែ **ពន្យល់** គឺចង់បញ្ជាក់ថា គ្មានអ្វីក្រៅពីការពន្យល់ទេ ក្នុងការឃោសនានយោបាយដើម្បីរកការគាំទ្រគំនិត បើអ្នកចាំទស្សនៈនេះគ្រប់ពេលវេលា វានឹងបានទៅជាផែនទីនាំគ្រប់សកម្មភាពនយោបាយរបស់អ្នក មិនឱ្យអ្នកធ្លាក់ចេញពីបាតគ្រឹះសុចរិតភាពបានឡើយ។
- ភាពអួតអាង ការបំផ្លើសបំផ្លោង ការអុជអាល ឆ្លៀតឱកាស ប្រជាភិថុត ដែលជាទម្លាប់របស់អ្នកនយោបាយខ្មែរទូទៅ ក៏ជាហេតុបង្កឱ្យមានអរិភាពក្នុងចិត្ត ជាហេតុធ្វើឱ្យមានការចង់ចាញ់ចង់ឈ្នះ ដែលអាចឈានទៅដល់ការបែកបាក់ជាតិផងដែរ។ ត្រូវចងចាំថា "បក្សដើម្បីជាតិមិនមែនជាតិដើម្បីបក្សទេ"។ ដូច្នេះ ដើម្បីគេចផុតពីផលអវិជ្ជមានខាងលើ ឥរិយាបថមួយ ដែលត្រូវយកមកជំនួសគឺ "ដាក់ខ្លួនឱ្យទាប ឫកពាឱ្យសុភាព តែការងារឱ្យណាស់" គឺមានតែ

សកម្មភាពជាក់ស្តែងប៉ុណ្ណោះដែលអាចបញ្ជាក់ពីឆន្ទៈពិតប្រាកដបាន។ **ការងារត្រូវតែលឿនជាងសម្តី**។

ឥឡូវ ពួកយើងបានយល់រួចហើយពីនយោបាយ និងបាតគ្រឹះនៃនយោបាយ តើអ្វី ដែលពួកយើងត្រូវយល់បន្ទាប់ទៅទៀត? នោះគឺជាចំណុចចាប់ផ្តើម។

ការចាប់ផ្តើមគឺជាផ្នែកសំខាន់នៃជោគជ័យ គ្មានការចាប់ផ្តើមក៏គ្មានជោគជ័យដែរ ប៉ុន្តែបើមានការចាប់ផ្តើមហើយ តែជាការចាប់ផ្តើមខុស ជោគជ័យនោះគឺមហន្តរាយ។ ដូច្នេះ បើយើងចាត់ទុកថា ជោគជ័យជារឿងសំខាន់ ចំណុចចាប់ផ្តើមក៏ជារឿងសំខាន់ដែរ។ យើងត្រូវតែ ពិនិត្យផ្ទៀងផ្ទាត់លើចំណុចចាប់ផ្តើមឱ្យល្អិតល្អន់ដើម្បីបញ្ជាក់ថា ពិតជាត្រូវចាប់ផ្តើមពីចំណុចនេះ យ៉ាងពិតប្រាកដមែន និងត្រូវធ្វើឱ្យច្បាស់ថា ជាចំណុចដែលអាចចេញដំណើរបាន និងជាហេតុនាំទៅដល់ជោគជ័យពិតប្រាកដមែន។ ចៀសវាងការដាំដើមស្វាយនៅលើដុំដែក ដែលគ្មានចំណុចចាប់ផ្តើមអាចចេញដំណើរបាន ឬដាំដើមស្លារំពឹងផ្លែផ្កាថាជាត្នោត។ ជាឧទាហរណ៍ គេបានប្រាប់ពលរដ្ឋថា ដើម្បីបំបាត់អំពើពុករលួយនៅប្រព័ន្ធតុលាការ គឺត្រូវចាប់ផ្តើមពីពលរដ្ឋគ្រប់គ្នាត្រូវឈប់សូក។ នេះគឺជាទស្សនៈមួយងាប់ឈឹង ដែលមិនអាចចាប់ផ្តើមបាន ដូចយកដើមឈើទៅដាំលើដុំដែក។

ឧទាហរណ៍មួយទៀត គេប្រាប់ពលរដ្ឋថា កាលណាពលរដ្ឋបោះឆ្នោតឱ្យគណបក្សគេ គេនឹងធ្វើសង្គមប្រជាធិបតេយ្យឱ្យប្រជាពលរដ្ឋ។ តើប្រជាធិបតេយ្យឯណា ត្រូវបានធ្វើឱ្យកើតឡើង ដោយអ្នកនយោបាយមួយក្រុមតូច ដោយខ្វះគ្រាប់ពូជ "**ការចូលរួម**" នោះ?

ដើម្បីធ្វើឱ្យច្បាស់ថា នេះគឺពិតជាចំណុចចាប់ផ្តើមត្រឹមត្រូវពិតប្រាកដមែន យើងត្រូវយកគោលដៅរបស់ពួកយើង មកត្រួតពិនិត្យម្តងទៀតសិន "**មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងនាមជាម្ចាស់**"។

ពិតណាស់ នេះគឺជាសង្គមប្រជាធិបតេយ្យ គឺជាមាតុភូមិមួយដែលពួកយើងទាំងអស់គ្នាជាម្ចាស់។ បើគោលដៅជាប្រយោជន៍របស់ពួកយើងទាំងអស់គ្នា ដូច្នេះពួកយើងទាំងអស់ត្រូវតែមានកាតព្វកិច្ចក្នុងការចូលរួមធ្វើ។ មានន័យថា គ្រាប់ពូជ គឺជាគ្រាប់ពូជ "**ការចូលរួម**"។ ដើម្បីឱ្យបានគ្រាប់ពូជ "**ការចូលរួម**" យើងត្រូវចាប់ផ្តើមពីការពន្យល់ពួកយើងទាំងអស់គ្នា ពីអត្ថន័យនៃ "**ប្រជាធិបតេយ្យ**" (ឱ្យយល់ពីសិទ្ធិ និងកាតព្វកិច្ចក្នុងនាមជាម្ចាស់) បើអ្នកចង់បានផ្លែស្វាយ ពិតណាស់ គ្រាប់ពូជត្រូវតែជាគ្រាប់ពូជស្វាយ បើយើងចង់បានសង្គមប្រជាធិបតេយ្យគឺ "**មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងនាមជាម្ចាស់**" ពិតណាស់ យើងត្រូវដាំគ្រាប់ពូជ "**ការចូលរួម**"។ ចុះការដាំគ្រាប់ពូជត្រឹមត្រូវតែម្យ៉ាង តើវាគ្រប់គ្រាន់ដែរឬទេ ដើម្បីឱ្យគ្រាប់ពូជនេះដុះលូតលាស់បានល្អ? ចម្លើយឆ្លើយថា ពិតជាមិនអាចបានទេ។ យើងត្រូវស្រោចទឹកបន្ថែមទៀត។

នៅទីនេះ អ្វីជាទឹក? ប្រជាធិបតេយ្យមិនមែនដើម្បីប្រជាធិបតេយ្យទេ ប៉ុន្តែគឺដើម្បីការរស់នៅក្នុងភាពសុខដុមរមនារបស់ពួកយើងទាំងអស់គ្នា។ បើយើងមានគ្រាប់ពូជ "**ការចូលរួម**" មកដាក់ដាំហើយ ប៉ុន្តែការចូលរួមនៃម្ចាស់សិទ្ធិ ដែលមានមូលដ្ឋានពិចារណាទន់ខ្សោយ តើសមិទ្ធផលដែលកើតពីការចូលរួម ជាសមិទ្ធផល ល្អត្រឹមត្រូវកើតដែរឬទេ? គឺពិតជាមិនអាចទេ។ ព្រះធម៌ជាមេរៀនត្រាស់ដឹងរបស់ព្រះពុទ្ធផ្តល់ឱ្យមនុស្សនូវមូលដ្ឋានវែកញែកដ៏ល្អិតល្អន់មួយ។ ដូច្នេះហើយ ការពន្យល់ដោយផ្អែកលើមេរៀនរបស់ព្រះពុទ្ធ ដើម្បីផ្តល់ឱ្យពួកយើងទាំងអស់គ្នានូវ សមត្ថភាពវែកញែក ជាផ្នែកទីពីរនៃចំណុចចាប់ផ្តើមរបស់ពួកយើង នេះគឺជាទឹក។
ចុះត្រឹមតែការដាក់ដាំ និងស្រោចទឹកលើគ្រាប់ពូជ តើវាប្រាកដដែរឬទេថា យើងនឹងទទួលបានផ្លែផ្កាដែលមានឱជារស? ចម្លើយឆ្លើយថា ពិតជាមិនបានទេ។ យើងត្រូវតែដាក់ជីបន្ថែមទៀត។ តើអ្វីជាជី? មានការចូលរួមហើយ ជាការចូលរួមរបស់មនុស្សដែលមានមូលដ្ឋានពិចារណាខ្ពស់ហើយ ពួកគេអាចមានសមត្ថភាពយល់បានហើយ ប៉ុន្តែ ពួកគេបំពានលើការយល់របស់ពួកគេ ព្រោះគេមានអគតិណាមួយ ចំណុចនេះគឺទាក់ទងនឹងសីលធម៌របស់អ្នកចូលរួម។ ត្រង់នេះចង់បញ្ជាក់ថា ការចូលរួមរបស់មនុស្សចេះដឹងខ្ពស់ ប៉ុន្តែគ្មានសីលធម៌ក៏ការចូលរួមនេះ មិនបានជាប្រយោជន៍ដែរ ជួនកាលនាំទៅការប្រទូសរ៉ាយគ្នាផង។ ហេតុនេះហើយ ការអប់រំឱ្យអ្នកចូលរួមមានសីលធម៌ គឺជាផ្នែកទីបីនៃចំណុចចាប់ផ្តើម។

គ្រាប់ពូជ “**ការចូលរួម**” អាចលូតលាស់ល្អ និងចេញជាផ្លែផ្កា ដែលមានឱជារសឆ្ងាញ់ គឺ “**មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងនាមជាម្ចាស់**” លុះត្រាតែគ្រាប់ពូជ “**ការចូលរួម**” នោះ ត្រូវមានការចូលរួមដោយពួកយើងទាំងអស់គ្នា ដែលមានមូលដ្ឋានវែកញែកខ្ពង់ខ្ពស់ និងប្រកបដោយសីលធម៌ផង។

សរុបខ្លឹមសារនៃចំណុចចាប់ផ្ដើមរបស់ពួកយើង គឺ ៖

- ពន្យល់ពលរដ្ឋយើងឱ្យស្គាល់ពីអត្ថន័យនៃ “ប្រជាធិបតេយ្យ” ដើម្បីឱ្យបានគ្រាប់ពូជ “**ការចូលរួម**”។
- ពន្យល់ពលរដ្ឋឱ្យមានមូលដ្ឋានវែកញែក ដោយផ្អែកលើមេរៀនរបស់ព្រះពុទ្ធ ដែលយើងអាចនិយាយថា ជាការទាញយកប្រយោជន៍ពីកិច្ចបដិបត្តិព្រះធម៌ ដើម្បីឱ្យគ្រាប់ពូជ “**ការចូលរួម**” រីកលូតលាស់ធំធាត់ឡើងឆាប់រហ័ស។
- ពន្យល់ពលរដ្ឋឱ្យមានសីលធម៌នោះ គ្រាប់ពូជ “**ការចូលរួម**” នឹងរីកលូតលាស់ឡើងឆាប់រហ័សប្រកបដោយផ្លែផ្កាដ៏មានឱជារស សម្រាប់ជាប្រយោជន៍ដល់ពួកយើងទាំងអស់គ្នា “**មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងនាមជាម្ចាស់**”។

អាចនិយាយសរុបឱ្យខ្លីម្យ៉ាងទៀតថា ចំណុចចាប់ផ្ដើមរបស់ពួកយើង គឺផ្ដើមចេញពីការពន្យល់ប្រជាពលរដ្ឋទៅលើគោលធំៗបីគឺ **ប្រជាធិបតេយ្យ កិច្ចបតិបត្តិព្រះធម៌** និង **សីលធម៌សង្គម**។

បន្ទាប់ពីចំណុចចាប់ផ្ដើមត្រូវបានដោះស្រាយរួចហើយ យើងនៅមានបញ្ហាមួយទៀត ដែលយើងត្រូវតែដោះស្រាយក្នុងដំណើរកសាងសុបិនរួមរបស់យើង គឺថា តើធនធានមនុស្សបែបណា ដែលនឹងត្រូវក្លាយទៅជាតំណាងឆន្ទៈរបស់ពួកយើង?

ចលនាស្ថូល គឺជាទ័ពស្រួចក្នុងការនាំមុខក្បួនដំណើររបស់ពួកយើងឆ្ពោះទៅរកសុបិនរួម ដែលជាគោលដៅរបស់ពួកយើង ។

ក្រុមស្នូលដែលនឹងក្លាយទៅជាតំណាងឆន្ទៈរបស់ពួកយើង ត្រូវមានយ៉ាងហោចណាស់នូវគុណសម្បត្តិគន្លឹះមួយចំនួន ៖

- គេត្រូវតែជាមនុស្សដែលស្គាល់ពីគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យច្បាស់លាស់។ ពាក្យដែលសំខាន់ជាងគេក្នុងឃ្លាមួយនេះ គឺ "**ស្គាល់**"។
- គេត្រូវតែជាមនុស្សដែលចាត់ទុកការងារក្នុងចលនានេះ ជាការងារអាទិភាពក្នុងជីវិតរបស់គេ។
- គេត្រូវយល់ដឹងថា តួនាទីនយោបាយ ដែលពួកយើងប្រគល់ឱ្យគេ មិនមែនជាមុខរបររកស៊ីទេ ប៉ុន្តែជាការទទួលខុសត្រូវ។ នេះជាអម្រែក។
- ពួកគេត្រូវស្គាល់អំពីចិត្តរបស់គេឱ្យបានច្បាស់ ថាតើគេពិតជាមានបំណងក្នុងការជួយដោះស្រាយបញ្ហារបស់ពលរដ្ឋទូទៅ មែនដែរឬទេ? វាត្រូវតែជាជំនក់ចិត្តមួយ ដែលបានក្លាយទៅជាទម្លាប់ទៅហើយ អ្នកដទៃមើលឃើញថាវាជាការលះបង់ ប៉ុន្តែចំពោះខ្លួនគេ វាជាការធ្វើបានយ៉ាងធម្មតាសោះ។ គេនឹងមិនធុញទ្រាន់ឡើយ គេនឹងមិននឿយហត់ឡើយ គេនឹងមិនបោះបង់ចោលការងារនេះឡើយ ព្រោះវាជាសេចក្ដីត្រូវការរបស់ជីវិតគេទៅហើយ។ អ្នកដែលមានបំណងក្នុងការជួយដោះស្រាយបញ្ហារបស់ប្រទេសជាតិ ត្រូវតែសួរខ្លួនឯងថា តើអ្នកមានចំណុចនេះហើយឬនៅ? នេះហើយ គឺជាការស្គាល់ខ្លួនឯងពិតប្រាកដ។ សូមរំលឹកពួកគេថា មិនមែនជាការងាយស្រួលទេដើម្បីស្គាល់ចិត្តខ្លួនឯង សូមកុំគិតងាយត្រង់ចំណុចនេះឱ្យសោះ **ការស្គាល់ចិត្តខ្លួនឯងជាការស្គាល់ដ៏កម្រ និងជាការស្គាល់ដ៏ប្រសើរ**។
- គេត្រូវតែជាមនុស្សដែលសុចរិត ស្អាតស្អំ ស្អប់អំពើអាក្រក់ ដោយខ្លួនឯងមិនប្រព្រឹត្តអំពើអាក្រក់ និងជាអ្នកបង្ក្រាបអំពើអាក្រក់របស់អ្នកដទៃយ៉ាងមុតមាំ។ គុណសម្បត្តិមួយនេះ គឺផ្តោតលើភាពជាគំរូ។ **សង្គមមួយស្អាតស្អំ គឺអាចផ្តើមចេញពីភាពស្អាតស្អំជាគំរូ របស់សមាជិកសង្គមម្នាក់**។
- គេត្រូវតែជាមនុស្សដែលមានទស្សនវិស័យ គឺមានទស្សនៈក្នុងការដោះស្រាយ ហើយមានសកម្មភាពជាក់ស្តែង ដើម្បីបម្រើទស្សនៈរបស់ខ្លួន ឱ្យក្លាយជាការពិតបាន។

ជាសរុប គុណសម្បត្តិរបស់តំណាងឆន្ទៈយើង គឺយ៉ាងហោចណាស់ពួកគេ ត្រូវមានគុណសម្បត្តិរបស់បេះដូង គឺជាមនុស្សស្រលាញ់ជាតិមាតុភូមិ ដោយហ៊ានលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីប្រយោជន៍ជាតិ ជាអ្នកសុចរិត ស្អាតស្អំ មិនប្រព្រឹត្តអំពើអាក្រក់ សូម្បីគ្មានអ្នកណាម្នាក់ដឹងក៏ដោយ មានចិត្តបង្ក្រាបអំពើអាក្រក់របស់អ្នកដទៃយ៉ាងមុតមាំ និងជាមនុស្ស ដែលនាំមុខដោយទស្សនវិស័យភ្លឺថ្លា។

តើយើងនឹងជ្រើសរើសអ្នកទាំងអស់នោះ មកពីណា? អ្នកទាំងនេះ គឺជ្រើសចេញពីក្នុងចំណោមអ្នកចូលរួមរបស់ពួកយើង ដោយផ្អែកលើគុណសម្បត្តិខាងលើ ជាខ្នាតវាស់វែង និងផ្អែកលើការភ្ញាក់រលឹករបស់បុគ្គលទាំងនោះផ្ទាល់ ដោយមិនអូសទាញ ឬអង្វរករឡើយ។ ការទទួលខុសត្រូវការងារណាមួយដែលយើងហៅថា "**តួនាទី**" គឺបានមកពីសកម្មភាពជាក់ស្តែងរបស់គេ ក្នុងការងារនោះ ដោយគ្មានការចាត់តាំង ឬផ្តល់ឱ្យជាមុនពីបុគ្គលណាមួយឡើយ។ "**តួនាទីរត់រកមនុស្ស មិនមែនមនុស្សរត់រកតួនាទីឡើយ**"។

ចំណុចចុងក្រោយ ដែលពួកយើងត្រូវច្បាស់លាស់អំពីការចូលរួមរបស់ពួកយើង គឺ ថាតើពួកយើងត្រូវចូលរួមធ្វើអ្វីខ្លះ? ហើយចូលរួមកម្រិតណា ដើម្បីសម្រេចសុបិនរួម "**មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងនាមជាម្ចាស់**" នោះឡើង?

**១. ការចូលរួមជាកម្លាំង**

**២. ការចូលរួមជាបញ្ញា**

**៣. ការចូលរួមជាថវិកា**

ការចូលរួមនេះ គឺផ្អែកទៅតាមលទ្ធភាព សមត្ថភាព ស្ថានភាពជាក់ស្តែង របស់ពួកយើងម្នាក់ៗ ដែលយើងអាចនិយាយបានថា "**លើកដាក់តាមកម្លាំង**" និងក្រោមបាវចនារបស់គណបក្សយើងគឺ "**រួមគិត រួមធ្វើ រួមទទួលខុសត្រូវ**"។

មកដល់ពេលនេះ យើងអាចមានចម្លើយច្បាស់លាស់ចំពោះសំណួរដែលសួរថា តើអ្នកត្រូវស្គាល់អ្វីខ្លះ ដើម្បីបញ្ជាក់ថា អ្នកពិតជាស្គាល់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ពិតប្រាកដមែន?

១. **គោលដៅ ៖** សុបិនរួមរបស់ពួកយើង “**មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងនាមជាម្ចាស់**” ដែលនឹងត្រូវធ្វើឱ្យស្តែងឡើងដោយយន្តការប្រាំបីចំណុច។

២. **ចំណុចចាប់ផ្តើម ៖** អ្វីៗទាំងអស់ត្រូវផ្តើមចេញពីការចូលរួមរបស់ប្រជាពលរដ្ឋ។

៣. **តវិយាបថនយោបាយ ៖** សុចរិតភាពជាបាតគ្រឹះ ដែលជាអត្តចរិតផង និងជាឧត្តមគតិផង ដែលជាខ្លឹមពិតប្រាកដ របស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។

៤. **ធនធានមនុស្ស ៖** គុណសម្បត្តិរបស់បេះដូង និងគុណសម្បត្តិខួរក្បាល ជាលក្ខណ:មិនអាចខ្វះបានសម្រាប់ចលនាស្នូល។

នៅមានរឿងមួយទៀត ដែលយើងត្រូវជជែកគ្នាអោយបានច្បាស់លាស់។ ថាតើនៅក្នុងចលនានយោបាយរបស់ពួកយើង អ្វីទៅជាជោគជ័យរបស់យើងម្នាក់ៗ និងអ្វីទៅជាជោគជ័យរបស់យើងទាំងអស់គ្នា? ហើយជោគជ័យទាំងពីរនេះវាមានទំនាក់ទំនងយ៉ាងម៉េចនឹងគ្នា? ចំពោះជោគជ័យរបស់យើងម្នាក់ៗក្នុងចលនានេះត្រូវសួរទៅកាន់ពួកយើងម្នាក់ៗដោយឡែកៗ ព្រោះវាគឺជាការទទួលខុសត្រូវរបស់យើងម្នាក់ៗ ដោយឡែកៗពីគ្នាដែរ។ រីឯជោគជ័យរបស់យើងទាំងអស់គ្នាក្នុងចលនានេះវិញ គឺត្រូវសួរទៅកាន់ពួកយើងទាំងអស់គ្នាព្រោះវាគឺជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា។ គ្មានអ្នកណាម្នាក់ទទួលខុសត្រូវចំពោះជោគជ័យ ឬបរាជ័យរបស់យើងទាំងអស់គ្នាក្នុងចលនានេះទេ។ “**គេមិនត្រូវសួរទៅកាន់ពួកយើងណាម្នាក់ថា តើអ្នកត្រូវធ្វើយ៉ាងម៉េចដើម្បីឱ្យសុបិនរួមរបស់យើងបានជោគជ័យនោះទេ ប៉ុន្តែគេអាចសួរថា តើអ្នកត្រូវចូលរួម យ៉ាងម៉េចដើម្បីឱ្យបានជាចំណែក ធ្វើឱ្យសុបិនរួមរបស់យើងបានជោគជ័យ?**” ម្នាក់ៗក្នុងចលនាយើង មានការទទួលខុសត្រូវត្រឹមតែចំណែក ដែលគេត្រូវចូលរួមតែប៉ុណ្ណោះ ដូច្នេះជោគជ័យរបស់គេម្នាក់ៗ គឺ ជោគជ័យក្នុងផ្នែកដែលគេទទួលខុសត្រូវនោះឯង។ នេះជាខ្លឹមសារធំណាស់នៃអត្ថន័យនៃជ័យជំនះ ដែលគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានកំណត់យក ហើយដែលខុសប្លែកខ្លាំងណាស់ ពីអត្ថន័យជោគជ័យ ដែលគណបក្សដទៃបានប្រកាន់យក។ ពួកយើងមួយចំនួន ដែលចំនួននោះតិចជាងហាសិបភាគរយបូកមួយ អាចមានជោគជ័យ នៅពេលដែលពួកយើងទាំងអស់គ្នាបរាជ័យ ព្រោះចំនួនហាសិបភាគរយបូកមួយនៃពួកយើង គេបានធ្វើឱ្យបរាជ័យការងាររៀងៗខ្លួនរបស់ពួកគេ។ សំណួរជាគន្លឹះ ដែលភ្ជាប់ពីជ័យជំនះរបស់យើងម្នាក់ៗ ទៅនឹង

ជ័យជំនះរបស់ពួកយើងទាំងអស់គ្នាគឺថា តើអ្នកមានជោគជ័យក្នុងការងាររបស់អ្នកហើយឬនៅ? ឧទាហរណ៍ ពួកយើងមិនតិចទេ ដែលមិនដែលបរាជ័យក្នុងការងាររបស់ពួកយើងទាល់តែសោះ ក្នុងនោះមានខ្ញុំម្នាក់ដែរ។ បរាជ័យគឺដូចជា ដាក់ដើមទុនក្នុងការរកស៊ីមុខជំនួញមួយខាត។ ខ្ញុំបានដាក់ដើមទុន កម្លាំងកាយ កម្លាំងប្រាជ្ញា កម្លាំងថវិកា ដើម្បីកិច្ចការពន្យល់រាស្ត្រ នេះជាការទទួលខុសត្រូវរបស់ខ្ញុំ។ ខ្ញុំតែងតែធ្វើការងារនេះជារៀងរាល់ថ្ងៃ មានមនុស្សជាបន្តបន្ទាប់ បានទទួលប្រយោជន៍ពីការងាររបស់ខ្ញុំ មានន័យថា ខ្ញុំបានធ្វើឱ្យជោគជ័យរួចហើយនូវការងាររបស់ខ្ញុំ។ សុបិនរួមរបស់យើង គឺ "**មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងនាមជាម្ចាស់**" មិនបានសម្រេចឡើង មិនមែនជាបរាជ័យរបស់ខ្ញុំទេ តែជាបរាជ័យរបស់យើងទាំងអស់គ្នា។ ត្រង់ចំណុចនេះ ខ្ញុំពិតជាច្បាស់លាស់ណាស់ថា ខ្ញុំពិតជាបានធ្វើការងាររបស់ខ្ញុំក្នុងចលនានេះប្រកបដោយជោគជ័យ ចុះចំណែកអ្នកវិញ តើអ្នកបានធ្វើឱ្យការងាររបស់អ្នកក្នុងចលនានេះ អោយបានជោគជ័យហើយឬនៅ? បើពួកយើង ហាសិបភាគរយបូកមួយឡើងទៅ សុទ្ធតែបានជោគជ័យក្នុងការងាររៀងៗខ្លួននោះ មានន័យថាជោគជ័យរួមរបស់ពួកយើងទាំងអស់គ្នា បានសម្រេចហើយ។ ន័យទាំងស្រុងក្នុងវគ្គនេះ ចង់បញ្ជាក់ថា បើជ័យជំនះរបស់ពួកយើងទាំងអស់គ្នាមិនបានសម្រេចឡើង គ្រប់អ្នកដែលបានធ្វើការងាររបស់ខ្លួនក្នុងចលនានេះត្រឹមត្រូវហើយ អ្នកគ្មានបរាជ័យក្នុងការងាររបស់អ្នកទេ មានតែអ្នកដែលរំពឹងថានឹងបានប្រយោជន៍ផ្ទាល់ខ្លួនទេ ដែលបរាជ័យក្នុងករណីនេះ។ នេះគឺជាលំអានរបស់ព្រះពុទ្ធ "**ព្យាយាមធ្វើការងារដែលខ្លួនត្រូវធ្វើ ឱ្យបានត្រឹមត្រូវ និងអស់ពីលទ្ធភាព រួចហើយញញឹមនឹងលទ្ធផលដែលខ្លួនទទួលបាន**"។

## នេះហើយគឺ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។

មកដល់ចំណុចនេះ ខ្ញុំសូមឆ្លៀតពេលលើកសំណួរកំប្លែងមួយសួរទៅកាន់អង្គសមាជ ៖ បើសិនជាខ្ញុំប្រើពាក្យថា *"អរគុណចំពោះបងប្អូនដែលបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រូបខ្ញុំ"* តើបងប្អូនមានអារម្មណ៍យ៉ាងម៉េចដែរ? មុខតែជាសំណើចដ៏ហួសចិត្តលាយឡំនឹងចម្ងល់ហើយ!

ម៉េចក៏ទៅជាអរគុណចំពោះអម្រែក ដែលខ្លួនបានទទួលទៅវិញ? ពិតជាគួរឱ្យហួសចិត្តមែន។ ជាការពិត ខ្ញុំនិយាយពាក្យថា"**អរគុណ**" មិនចេញទេ ព្រោះវាគ្មាននៅក្នុងចិត្តរបស់ខ្ញុំ ប៉ុន្តែវាគឺជាមនសិការមួយដែលរំលឹក

ខ្ញុំថា ការទុកចិត្តមានកាន់តែច្រើនហើយ ការងារក៏កាន់តែធ្ងន់ធ្ងរដែរ ការទទួលខុសត្រូវក៏កាន់តែធំដែរ នេះគឺជាសេចក្ដីសង្ឃឹមរបស់មនុស្សយ៉ាងច្រើនចំពោះខ្ញុំ។ ការសម្លាប់សេចក្ដីសង្ឃឹមធំៗរបស់មនុស្សគឺជាទារុណកម្មដ៏ធ្ងន់ធ្ងរណាស់ចំពោះមនុស្សទាំងនោះ។ អាចនិយាយបានថា ជាការស្លាប់ទាំងរស់ផង ក៏ថាបាន។ ខ្ញុំមិនបានធ្វើការសច្ចាអ្វីចំពោះមុខបងប្អូនទេ ខ្ញុំគ្រាន់តែអាចនិយាយបានថា មនុស្សដែលមើលងាយចំពោះការទុកចិត្តរបស់មនុស្សដទៃ គឺជាមនុស្សថោកទាបបំផុត។ មនុស្សដែលសម្លាប់សេចក្ដីសង្ឃឹមធំៗរបស់មនុស្សគឺជាមនុស្សដែលបានប្រព្រឹត្តទោសកំហុសយ៉ាងធ្ងន់ធ្ងរបំផុត។ **ពួកយើងគ្រប់គ្នាមិនត្រូវអត់អោនទោសចំពោះមនុស្សដែលបានប្រព្រឹត្តកំហុសបែបនេះទេ។**

ក្នុងចិត្តរបស់ខ្ញុំគ្មានទេពាក្យថា “អរគុណ” ចំពោះគ្រប់សកម្មភាពដែលបងប្អូនបានចូលរួមក្នុងចលនារបស់ពួកយើង ព្រោះវាជាកាតព្វកិច្ចដែលពួកយើងទាំងអស់គ្នាត្រូវតែចូលរួមធ្វើ ដើម្បីប្រយោជន៍រួមរបស់ពួកយើង ដើម្បីប្រយោជន៍របស់ជាតិមាតុភូមិយើង។ ប៉ុន្តែជំនួសឱ្យពាក្យថា “អរគុណ” គឺជាទឹកចិត្តស្ញើចសរសើរ គោរពកោតក្រែង ទៅវិញទេ ដែលយើងមានរវាងគ្នានិងគ្នា ពីព្រោះពួកយើងជាទូទៅ កំពុងតែស្ថិតក្នុងស្ថានភាពមិនល្អ តែនៅតែបានបំពេញកាតព្វកិច្ច ដែលជាការទទួលខុសត្រូវក្នុងនាមជាម្ចាស់ប្រទេស នៅពេលដែលពលរដ្ឋដ៏ច្រើនលើសលប់ផ្សេងទៀត មិនមានការទទួលខុសត្រូវត្រង់ចំណុចនេះទាល់តែសោះ។

ដូច្នេះ ពិតណាស់ វាគឺជាទឹកចិត្តដែលគួរឱ្យគោរពកោតសរសើរ។ តើអ្នកណាមួយអាចបដិសេធបានថា នៅក្នុងគ្រប់សរសៃឈាមដែលចិញ្ចឹមចលនានយោបាយរបស់យើងឱ្យរីកធំធាត់មកដល់ពេលនេះ គ្មានការចូលរួមរបស់បងប្អូននោះ? ដូច្នេះ ការចូលរួមរបស់បងប្អូនមានតម្លៃបំផុតសម្រាប់អាយុជីវិតនៃចលនារបស់យើងក្នុងដំណើរឆ្ពោះទៅសម្រេចសុបិនរួមរបស់ពួកយើងគឺ **“មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងនាមជាម្ចាស់”។**

នាឱកាសចុងក្រោយនៃសុន្ទរកថានេះ ខ្ញុំសូមរំលឹកចលនាយើងថា ចលនាមួយអាចបុកទម្លុះឧបសគ្គទៅដល់គោលដៅបាន លុះត្រាតែចលនានោះមានសភាព **ណែន ស្វាហាប់ មុឺងមាត់ មុតមាំ** មិនខ្លាចញញើតចំពោះ

ឧបសគ្គអ្វីទាំងអស់ ដែលជាលក្ខណៈផុសចេញពីប្រភពតែមួយគត់គឺ **ទំនុកចិត្ត**។ ដើម្បីឱ្យមានទំនុកចិត្ត បងប្អូនត្រូវមានគុណសម្បត្តិបីយ៉ាង ៖

១. គឺច្បាស់ពីចិត្តខ្លួនឯងថា បងប្អូនគ្មានចង់បានផលប្រយោជន៍ផ្ទាល់ខ្លួនទាល់តែសោះពីចលនានេះ។ ទោះបីជាសួរខ្លួនឯង មួយម៉ឺនដង មួយសែនដង មួយលានដង ក៏បេះដូងរបស់បងប្អូននៅតែឆ្លើយថា គ្មានចង់បានអ្វី ជាប្រយោជន៍ផ្ទាល់ខ្លួនទាល់តែសោះ ពីចលនានេះ។

២. ច្បាស់លាស់លើរបស់ដែលខ្លួនកាន់ ៖ ស្គាល់ច្បាស់ពីគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ដែលខ្លួនចូលរួម ច្បាស់លាស់ពីទស្សនៈដែលខ្លួនការពារ យល់ល្អិតល្អន់ពីទស្សនៈដែលខ្លួនបានបង្កើត។

៣. ច្បាស់លាស់ពីរបស់ដែលអ្នកដទៃមាន ៖ ច្បាស់ពីចិត្តរបស់គូប្រកួតរបស់យើង អាចប្រៀបធៀបបាន យ៉ាងច្បាស់លាស់ពីចិត្តរបស់យើង នឹងចិត្តរបស់គូប្រកួតរបស់យើង។ ច្បាស់លាស់ពីទស្សនៈ សមត្ថភាពបង្កើតទស្សនៈ ចន្លោះប្រហោងនៃទស្សនៈរបស់គូប្រកួតរបស់យើង។

ជាទីបញ្ចប់នេះខ្ញុំមានពាក្យមួយឃ្លាទៅកាន់បងប្អូនជនរួមឈាមទូទាំងប្រទេសដែលវាមានលក្ខណៈជាសំណួរផង និងជាសំណូមពរផងគឺ "**តើបេះដូងរបស់បងប្អូន អាចចាត់ទុកជនរួមឈាមយើងទាំងអស់គ្នា ជាសមាជិកគ្រួសាររបស់បងប្អូនផង បានដែរឬទេ?**"

**សូមអរគុណ**!